ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៤១៦

ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦

សាលក្រមលេខ៖ ២៥៩ "ខ"

ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧

# កំណត់ហេតុសវនាការ

# សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណ: នៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តកំពង់ស្ពឺ នាថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៧ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] អនុប្រធាននិងជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

**មេធាវីការពារសិទ្ធិ**

លោក [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ: [redacted] ស្រីស្ងត់

លោកស្រី [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ: [redacted]ទ្ធី ហៅ ធី ,ឈ្មោះ: [redacted]យឿន ហៅ អាយួន និងឈ្មោះ: [redacted]សំអុល។

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៤១៦ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ ទាក់ទងនឹងជនជាប់ចោទ:

១.ឈ្មោះ: [redacted] **ឌុទ្ធី ហៅ ធី** ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករអាឈើ ទីកន្លែងកំណើតនៅភូមិត្រពាំងអោប ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ: [redacted](ស) ម្តាយឈ្មោះ: [redacted] (ស) ប្រពន្ធឈ្មោះ: [redacted] ឬ [redacted] មានកូន ០៣នាក់ ប្រវត្តិទោស[illegible] គ្មាន ជានីតិជន។(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៥១៨/០៥.០៨.២០១៦)

២.ឈ្មោះ [redacted] **ឃឿន ហៅ អាឃួន** ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរ ជាងធ្វើផ្ទះ ទីកន្លែងកំណើតនៅភូមិអញ្ចាញ ឃុំចេកចូក ស្រុកបូរីជលសារ ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០៣នាក់ ប្រវត្តិទោសពីមុន គ្មាន ជានីតិជន។

(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៥០២/០៥.០៨.២០១៦)

៣.ឈ្មោះ [redacted] **សំអុល ហៅ** [redacted] **សំអុល** ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូមិបឹងព្រៃធំ ឃុំពេជ្រសារ ស្រុកកោះអណ្តែត ខេត្តតាកែវ សទីលំនៅបច្ចុប្បន្ននៅភូ[redacted]ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ [redacted] ប្រវត្តិទោសពីមុន គ្មាន ជានីតិជន។(គេចខ្លួន)

ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ , ៣៦០ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

៤.ឈ្មោ[redacted] **ស្រីស្ងួត** ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីកន្លែងកំណើតនៅភូមិក្រាំងល្ពង ឃុំមហាសាំង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ននៅភូមិដំបងវិញ ឃុំ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted](រ) ប្តីឈ្មោះ [redacted] ប្រវត្តិទោសពីមុន គ្មាន ជានីតិជន។ (ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៤៨១/ ១២.០៧.២០១៦)

ជាប់ចោទពីបទៈ សមគំនិត ក្នុងអំពើ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, ៣៥៣, ៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

៥.ឈ្មោះ [redacted] **ម៉ុន្លា** ភេទប្រុស អាយុ ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរ យោធា ទីកន្លែងកំណើតនៅភូមិព្រៃសាគុំ ឃុំព្រៃធំ ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោ[redacted](ស) ម្តាយឈ្មោះ[redacted] ប្រពន្ធ ឈ្មោះ[redacted]មានកូន ០២នាក់ ប្រវត្តិទោសពីមុន គ្មាន ជានីតិជន។



CamScanner

(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៥២២/០៥.០៨.២០១៦)

ជាប់ចោទពីបទៈ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិផ្សារកន្ទួត ឃុំសង្កែ សាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ស៊ីណាត ភេទស្រី អាយុ ៣៣ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិក្រូចសើច ឃុំពុកឬស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted]ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ [redacted](រ) ប្តីឈ្មោះ[redacted]ស) មានកូន ០២នាក់ ប្រវត្តិទោសពីមុន គ្មាន ជានីតិជន។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅៈ**

កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ វេលាម៉ោង ២០:២៥នាទី ស្ថិតនៅចំណុចខាងជើងផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ មានករណី លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត មួយបានកើតឡើង ដែលបង្កឡើងដោយឈ្មោះ [redacted]សំអុល , ឈ្មោះ[redacted]វុទ្ធី និងឈ្មោះ [redacted]យឿង ដែលបានធ្វើសកម្មភាពប្រើប្រាស់អាវុធម៉ាក AK ជាមធ្យោបាយបណ្តាលឲ្យជនរងគ្រោះឈ្មោះ[redacted] ជឿន ជាម្ចាស់ផ្ទះបានបាត់បង់ជីវិត។ ក្រោយពេលធ្វើសកម្មភាពជនត្រូវចោទទាំងបីខាងលើបានរត់គេខ្លួនបាត់។ ចំពោះឈ្មោះ [redacted] ម៉ុន្នា បានធ្វើសកម្មភាពលក់អាវុធម៉ាក AK ទៅឲ្យឈ្មោះ[redacted] សំអុល ហើយជននេះក៏បានយកទៅលក់ឲ្យឈ្មោះ[redacted]រី និងឈ្មោះ [redacted] វ៉ែន បន្តទៀត ដោយឡែកឈ្មោះ ឌី និងឈ្មោះ វ៉ាន់ ក៏មានជាប់ពាក់ពន្ធ័ជាមួយនិងឈ្មោះ[redacted]សំអុល ក្នុងការចែកចាយអាវុធដោយគ្មានការអនុញ្ញាតផងដែរ។ មុននិងធ្វើសកម្មភាពឈ្មោះ [redacted] ស្រីសួគ៌ ត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted]សំអុល បានទិញម្ហូបអាហាររៀបចំបាយទឹក ហើយថែមទាំងបានជូនឈ្មោះ [redacted] សំអុល ដោយជិះម៉ូតូទៅ ហើយក៏បានត្រឡប់មកវិញមុនផងដែរ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ ៧៣៤ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញដីកាដំណោះស្រាយលេខៈ ១០២ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ ។

-បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះបន្តលេខៈ ៥៤០ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧ របស់ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ ។



CamScanner

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted] វុទ្ធី ហៅ ធី បានឆ្លើយនាពេលសវនាការថា: កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ៥:៣០នាទីល្ងាច ឈ្មោះ[redacted]សំអុល បានហៅ ខ្លួនទៅផឹកនៅផ្ទះរបស់វាជាមួយឈ្មោះ[redacted] យឿង ហៅ អាយូន នៅពេលផឹកស៊ីឈ្មោះ[redacted] សំអុល បានបបួលខ្លួនទៅប្លន់ផ្ទះជាងមាស ពេលនោះឈ្មោះ [redacted] សំអុល បានឌុបពួកខ្លួនទៅដល់ក្រោយផ្ទះជាងមាស ហើយមិនថាយកកាំភ្លើងមកពីណានោះទេ យកឲ្យឈ្មោះ [redacted] យឿង ហៅ អាយូន កាន់មួយដើម និងឈ្មោះ[redacted] សំអុល កាន់មួយដើម ពេលឈ្មោះ [redacted] សំអុល ក៏បានកាត់ខ្សែលួសចំនួន ២ខ្សែ ហើយឈ្មោះ[redacted] សំអុល ជាអ្នកចូលមុនគេ បន្ទាប់មកគឺឈ្មោះ[redacted] យឿន ហៅ អាយូន និងខ្លួនជាអ្នកចូលក្រោយគេ ដោយមិនបានកាន់អ្វីនៅដៃនោះទេ ពេលចូលទៅ ដល់ក្រោយផ្ទះជាងមាសឈ្មោះ [redacted] សំអុល បានជួបនិងម្ចាស់ផ្ទះ និងបានប្រតាយប្រតប់គ្នា ហើយឈ្មោះ [redacted] សំអុល បានបាញ់ម្ចាស់ផ្ទះចំនួន ០១គ្រាប់ បន្ទាប់មកឈ្មោះ[redacted] យឿន ហៅ អាយូន បានបាញ់ទៅម្ចាស់ផ្ទះចំនួន ០១គ្រាប់ទៀត ខ្លួនឃើញដូចនេះរត់ចេញតែម្តង តែពេលរត់ចេញក៏ឮសំឡេងបាញ់ ០១គ្រាប់ទៀត តែមិនដឹងថាអ្នកណាជាអ្នកបាញ់នោះទេ។ ខ្លួនពិតជា បានចូលប្លន់ជាមួយឈ្មោះ[redacted]សំអុល និងឈ្មោះ [redacted] យឿង ហៅ អាយុយូន ចំនួន ០៣លើក ពិតប្រាកដមែន។ ពីមុនមកខ្លួនមិនដែលស្គាល់ឈ្មោះ[redacted] ម៉ុន្ថា នោះទេ ទើបតែស្គាល់នៅ ពេលដែលសមត្ថកិច្ចឃាត់ខ្លួនប៉ុណ្ណោះ ចំពោះឈ្មោះ [redacted] ស្រីសួគ៌ មិនបានចូលរួមការប្លន់របស់ពួកខ្លួនឡើយ។

-ជនជាប់ចោទឈ្មោះ[redacted] យឿង ហៅ យូន បានឆ្លើយនាពេលសវនាការថា: កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ៥:៣០នាទីល្ងាច ឈ្មោះ [redacted] សំអុល បានហៅ ខ្លួនទៅផឹកនៅផ្ទះរបស់វា ពេលផឹកស៊ីនោះមានឈ្មោះ[redacted] សំអុល ឈ្មោះ [redacted] វុទ្ធី ហៅ ធី និងរូបខ្លួន មិនមានឈ្មោះ[redacted] ស្រីសួគ៌ និងឈ្មោះ[redacted] ម៉ុន្ថា នោះទេ នៅពេលផឹកស៊ីឈ្មោះ [redacted] សំអុល បានបបួលខ្លួនទៅប្លន់ផ្ទះជាងមាស នៅចម្ងាយពីផ្ទះរបស់ឈ្មោះ [redacted] សំអុល ប្រហែល ១គីឡូដី ពេលនោះឈ្មោះ [redacted] សំអុល បានឌុបខ្លួននិងឈ្មោះ [redacted] វុទ្ធី ហៅ ធី ទៅដាក់នៅក្រោយផ្ទះរបស់ជាងមាស ហើយឈ្មោះ [redacted] សំអុល បានជិះម៉ូតូទៅយកកាំភ្លើង ចំនួន ២ដើម តែមិនយកមកពីកន្លែងណានោះទេ ហើយបានឲ្យទៅឈ្មោះ [redacted] វុទ្ធី ហៅ ធី ~~កាន់មួយដើម~~ ពេលនោះឈ្មោះ[redacted]សំអុល បានកាត់ខ្សែលួសចំនួន ២ខ្សែ ហើយ ឈ្មោះ[redacted] សំអុល ជាអ្នកចូលមុនគេ បន្ទប់មកខ្លួនចូលទៅតាមក្រោយ ហើយឈ្មោះ[redacted] វុទ្ធី ហៅ ធី ចូលមកដែរ ពេលចូលទៅដល់ឈ្មោះ [redacted] សំអុល បានជួបម្ចាស់ផ្ទះហើយបានប្រតាយប្រតប់គ្នាជាមួយឈ្មោះ [redacted] សំអុល ក៏បានបាញ់ទៅលើម្ចាស់ផ្ទះចំនួន ១គ្រាប់ ហើយខ្លួនដូចនេះ ក៏បាន បាញ់ឡើងលើចំនួន ១គ្រាប់ ហើយឈ្មោះ[redacted]សំអុល ក៏បានបាញ់ចំនួន ០១គ្រាប់ទៀត ទៅលើជនរងគ្រោះ ខ្លួនក៏រត់ចេញមកតែម្តង។ ហើយខ្លួនមិនដែលស្គាល់ឈ្មោះ [redacted]

នោះទេ គឺខ្លួនទើបតែស្គាល់នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនមកប៉ុណ្ណោះ នៅក្នុងករណីប្លន់នៅភូមិជំនាប់ ឃុំសង្កែសាទប ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺនោះ គឺមានឈ្មោះ [redacted] សំអុល ឈ្មោះ [redacted] វុទ្ធី ហៅ ធី និងរូបខ្លួនតែប៉ុណ្ណោះ មិនមានឈ្មោះ [redacted] ស្រីសូត៌ និងឈ្មោះ [redacted] ម៉ុន្ថា នោះទេ។ ខ្លួននិងឈ្មោះ [redacted] សំអុល ឈ្មោះ [redacted] វុទ្ធី ហៅ ធី ធ្លាប់ប្លន់ចំនួន ៣លើកមកហើយ លើកទីមួយមានឈ្មោះ [redacted] ប៊ុនធឿន ឈ្មោះ [redacted] សំអុល ឈ្មោះ [redacted] វុទ្ធី ហៅ ធី និងរូបខ្លួន តែមិនបានធ្វើសកម្មភាពប្លន់នោះទេ ព្រោះខ្លួនជាអ្នកបង្កើលមិនឲ្យប្លន់ និងលើកទី ២ និងលើកទី៣ គឺមានតែបីនាក់ គឺឈ្មោះ [redacted] សំអុល ឈ្មោះ [redacted] វុទ្ធី ហៅ ធី និងរូបខ្លួន។ ចំពោះចម្លើយរបស់ដែលខ្លួន បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ បានសួរខ្លួនថា [redacted] ស្រីសូត៌ បានឧបឈ្មោះ [redacted] សំអុល មកកន្លែងប្លន់មែនឬទេ ពេលនោះខ្លួនគ្រាន់តែឆ្លើយប្រហែលហើយ ហើយខ្លួនបានបដិសេធ ចម្លើយនេះតាំងពីដំណាក់កាលតំណាងអយ្យការ និងចៅក្រមស៊ើបសួររួចម្តងហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ស្រីសូត៌ បានឆ្លើយនាពេលសវនាការថា: កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ៥ទៅ៦ល្ងាច នៅក្នុងផ្ទះរបស់ខ្លួន មានឈ្មោះ [redacted] យឿន ហៅ អាយូន ឈ្មោះ [redacted] វុទ្ធី ហៅ ធី បានផឹកស៊ីជាមួយប្តីរបស់ខ្លួនឈ្មោះ [redacted] សំអុល ពេលនោះខ្លួនបានទៅទិញស្រាយកមកឲ្យពួកគាត់ផឹកនៅខាងក្រោយផ្ទះ ក្រោយពីទិញរួចហើយ ខ្លួនបានចូលទៅក្នុងផ្ទះមើលទូរទស្សន៍ និងចាក់ចម្រៀងស្តាប់នៅក្នុងផ្ទះ លុះដល់ម៉ោងប្រហែល ៦ល្ងាច ឈ្មោះ [redacted] យឿង ហៅ អាយូន និងឈ្មោះ [redacted] វុទ្ធី ហៅ ធី និងប្តីខ្លួនបានជិះម៉ូតូចេញទៅក្រៅបាត់ទៅ តែខ្លួនមិនដឹងថាទៅណានោះទេ រហូតមកដល់ម៉ោង ៨ភ្លឺ ទើបគាត់ត្រឡប់មកវិញ ហើយក៏ដោះអាវចូលដេកធម្មតា។ ចំពោះឈ្មោះ [redacted] វុទ្ធី ហៅ ធី និងឈ្មោះ [redacted] យឿន ហៅ អាយូន ខ្លួនស្គាល់ព្រោះពួកគាត់ជាជាងធ្វើផ្ទះឲ្យខ្លួន ហើយតែងតែដាំបាយឲ្យពួកគាត់ហូបពេលធ្វើផ្ទះ។ ចំពោះឈ្មោះ [redacted] ម៉ុន្ថា ខ្លួនធ្លាប់ស្គាល់ ព្រោះពីមុនខ្លួនរស់នៅក្នុងបន្ទាយទាហាននៅត្រពាំងក្រឡឹង ហើយគាត់ជាទាហាននៅទីនោះ។ នៅថ្ងៃកើតហេតុខ្លួននៅផ្ទះមិនឧបប្តីខ្លួនឈ្មោះ [redacted] សំអុល ទៅម៉ុំផ្ទះជាមាសនោះទេ។ ខ្លួនមិនដែលដឹងថាខ្លួនប្លន់គេជាច្រើនលក់នោះដែរ។

-ជនជាប់ចោទឈ្មោះ [redacted] ម៉ុន្ថា បានឆ្លើយនាពេលសវនាការថា: កាលពីឆ្នាំ២០១៤ នៅខេត្តរតនៈគីរី ឈ្មោះ [redacted] សំអុល បានមកលេងកន្លែងស្នាក់នៅរបស់ខ្លួន ហើយបានឃើញកាំភ្លើងចាស់ច្រេះចាប់ ដែលខ្លួនទុកចោលនៅក្រោយផ្ទះ ហើយបានសុំខ្លួនថាយកកែច្នៃ ធ្វើកាំភ្លើងបាញ់សត្វ តែខ្លួនមិនឲ្យ ហើយឈ្មោះ [redacted] សំអុល ក៏បានត្រឡប់ទៅវិញ ក្រោយមកក៏បានមកម្តងទៀត ហើយបានសុំកាំភ្លើង ចាស់របស់ខ្លួនម្តងទៀត ពេលនោះខ្លួនគិតថាកាំភ្លើងនោះចាស់ហើយ ប្រើក៏មិនបានទៀត ដូច្នេះខ្លួនបានឲ្យកាំភ្លើងនោះទៅឈ្មោះ [redacted] សំអុល ទៅ តាំងពីថ្ងៃនោះមកខ្លួនមិនដែល បានជួបឈ្មោះ [redacted] សំអុល នោះទេ។

ដីកាកោះរបស់តុលាការខេត្តរតនៈគីរី ឲ្យខ្លួនទៅបំភ្លឺនៅតុលាការពាក់ពន្ធ័និងកាំភ្លើងរបស់ខ្លួន ដែលបានឲ្យទៅឈ្មោះ [redacted]សំអុល នោះ ក្រោយពីបំភ្លឺរួចមកតុលាការបានឲ្យខ្លួនត្រឡប់មកវិញ។ រហូតដល់មានករណីប្លន់ស្រុក ឌីក៏ល់ក៏ខ្លួនមិនបានដឹងនោះដែរ ស្រាប់តែមានដីកាបញ្ជាឲ្យចូលខ្លួន ហើយបានចាប់ឃាត់ខ្លួនតែម្តង ចំពោះករណីនេះខ្លួនមិនបានដឹងនោះទេ ហើយក៏មិនដែលបានលក់កាំភ្លើងឲ្យឈ្មោះ [redacted]សំអុល នោះដែរ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ស៊ីណាត បានឆ្លើយនាពេលសវនាការថា: កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ៦ជាងល្ងាច ខ្លួនកំពុងផ្ទះជាមួយកូននៅខាងមុខផ្ទះ ហើយប្តីរបស់ខ្លួននៅដងទឹកខាងក្រោយផ្ទះ ពេលនោះបានឮសំឡេងប្តីរបស់ខ្លួនស្រែកថាចោរប្លន់ហើយ ពេលនោះខ្លួនក៏បានរត់ទៅមើល តែពេលទៅដល់ប្តីរបស់ខ្លួនដេកដួលនៅនិងដីទៅហើយ ហើយខ្លួនក៏បាននាំគាត់ទៅមន្ទីរពេទ្យ ហើយប្តីរបស់ខ្លួនក៏បានស្លាប់បាត់ដែរ ។ ខ្លួនទាមទារសំណងជំងឺចិត្តចំនួន ៥០.០០០(ប្រាំម៉ឺនដុល្លារ)។

-សាក្សីឈ្មោះ [redacted] ពយ បានឆ្លើយនាពេលសវនាការថា:កាលពីថ្ងៃខែមិនចាំឆ្នាំ ២០១៦ វេលាម៉ោង ៧:៣០នាទីល្ងាច ខ្លួនកំពុងតែអង្គុយមើលទូរទស្សន៍ស្រាប់តែប្រជាការពារភូមិឈ្មោះ [redacted] បិយ បានទូរសព្ទមកប្រាប់ថា មានគេប្លន់ក្នុងភូមិ ពេលលឺដូច្នេះ ខ្លួនក៏បានបិទទូរសព្ទ័រួចខ្លួនក៏ជិះម៉ូតូទៅកន្លែងកើតហេតុតែម្តង។ ពេលដែលខ្លួនទៅដល់កន្លែងកើតហេតុ ខ្លួនមិនបានឃើញជនរងគ្រោះទេ ព្រោះតជនរងគ្រោះត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យបាត់ទៅហើយ ហើយខ្លួនក៏ការពារផ្ទះរបស់ជនរងគ្រោះរហូតទល់ភ្លឺ ទើបពួកខ្លួនត្រឡប់មកផ្ទះរៀងៗខ្លួន រឿងអ្វីទៀតខ្លួនមិនបានដឹងនោះទេ។ គ្រាន់តែនៅពេលទៅកន្លែងកើតហេតុនោះខ្លួនបានជិះកាត់មុខផ្ទះរបស់ឈ្មោះ[redacted]ស្រីសួតិ ហើយបានឃើញឈ្មោះ សុខ ស្រីសួតិ នៅផ្ទះ។

-សាក្សីឈ្មោះ សេង សាម៉េត បានឆ្លើយនាពេលសវនាការថា: ខ្លួនគ្រាន់តែដឹងថា នៅថ្ងៃកើតហេតុឈ្មោះ [redacted] ស្រីសួតិ នាងនៅផ្ទះតាំងពីព្រឹករហូតដល់ម៉ោង ៧យប់ រឿងអ្វីផ្សេងទៀតខ្លួនមិនបានដឹងនោះទេ។

-សាក្សីឈ្មោះ[redacted]សុផៃ បានឆ្លើយនាពេលសវនាការថា: ខ្លួនជាឧត្តមសេនីយ៍ទោ ជាតំណាងរបស់អង្គភាពបញ្ជាការដ្ឋានរថក្រោះ សូមបញ្ជាក់ថាឈ្មោះ [redacted] សំអុល ដែលបានឆ្លើយថាឈ្មោះ [redacted] ម៉ុន្ថា ជាអ្នកលក់កាំភ្លើងឲ្យកាលពីឆ្នាំ២០១៤ នោះគឺមិនមែនជាការពិតនោះទេ ព្រោះតែអង្គភាពរបស់ខ្លួនទើបតែបាត់កាំភ្លើងកាលពីឆ្នាំ២០១៦ ដោយអង្គភាពបានសង្ស័យទៅលើឈ្មោះ [redacted] សំអុល ជាអ្នកគាស់ឃ្លាំងលួចកាំភ្លើងចំនួន ៨ដើម ពីអង្គភាពអាសេអូ។ ក្រោយពីបាត់កាំភ្លើងចំនួន ៨ដើមនោះ អង្គភាពបានបង្កើតគណកម្មការ ដើម្បីត្រួតពិនិត្យលើបាត់បង់កាំភ្លើង ក្រោយពីការពិនិត្យរួចមកឃើញថា កាំភ្លើងដែលបាត់នោះមានលេខដូចទៅនឹងកាំភ្លើងដែលសមត្ថកិច្ចរកឃើញនោះពិតមែន។

-សាក្សីឈ្មោះ [redacted] មិនបានចូលសវនាការទេ តាមអំណានចម្លើយនៅដំណាក់កាលចៅក្រមស៊ើសួរថា កាលពីថ្ងៃខែមិនចាំឆ្នាំ២០១៦ វេលាម៉ោង ៨:០០នាទី ខ្លួនកំពុងតែមើលទូរទស្សន៍ស្រាប់តែលឺសំឡេងគេវាយគ្នា ពេលលឺដូច្នេះខ្លួនក៏បើកបង្អួចមើលក៏ឃើញគេវាយគ្នា ខ្លួនក៏បិទបង្អួចទៅព្រោះខ្លាចគេបាញ់ត្រូវខ្លួន ហើយគេវាយគ្នានោះមានគ្នាប៉ុន្មាននាក់នោះខ្លួនមិនបានដឹងទេ។

-សាក្សីឈ្មោះ [redacted] ហាន មិនបានចូលសវនាការទេ តាមអំណានចម្លើយនៅដំណាក់កាលចៅក្រមស៊ើសួរថា កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ វេលាម៉ោង ៧:០០នាទី ខ្លួនកំពុងតែក្រាលកន្ទេលដេកស្រាប់តែលឺសមឡេងស្រែកថា ជួយផង១ ក្រោយមកលឺស្ងួផ្ទុះ តែខ្លួនស្មានតែគេបាញ់ផាវក៏រត់ទៅមើល ពេលទៅដល់ក៏ឃើញមានមនុស្សម្នាក់ពាក់អាវប៉ាក់ដៃវែង ឈរកាន់កាំភ្លើងវេង។ ពេលឃើញដូច្នេះខ្លួនក៏ស្រែកឲ្យគេជួយ រួចមកវាក៏បាញ់សំទៅជនរងគ្រោះ ០១គ្រាប់ទៀត រួចវាក៏រត់ទៅក្រោយផ្ទះជនរងគ្រោះបាត់ទៅ។

-សាក្សីឈ្មោះ [redacted] គឹមស៊ាង មិនបានចូលសវនាការទេ តាមអំណានចម្លើយនៅដំណាក់កាលចៅក្រមស៊ើសួរថា កាលពីថ្ងៃខែមិនចាំ ឆ្នាំ ២០១៦ វេលាម៉ោង ៧:០០នាទី ខ្លួនកំពុងតែមើលទូរទស្សន៍ស្រាប់តែលឺសំឡេងកាំភ្លើង គេបាញ់ចំនួន ០៣គ្រាប់ ពេលលឺដូច្នេះខ្លួនស្មានតែគេអុជផាវក៏រត់ទៅមើល ពេលទៅដល់ក៏ឃើញមនុស្សចំនួន ០៣នាក់ ម្នាក់ពាក់ខ្មៅដៃកាន់កាំភ្លើង និងពីរនាក់ទៀតឃើញចេញមកពីក្នុងផ្ទះបាយ ពេលនោះក៏លឺសំឡេងឈ្មោះ [redacted] ស៊ីណាត ស្រែកថាជួយ១ ចោរប្លន់ហើយ១ ពេលលឺដូច្នេះខ្លួនក៏រត់ទៅផ្ទះបាត់ទៅ។

-សាក្សីឈ្មោះ [redacted] សុភណ្ឌ័ មិនបានចូលសវនាការទេ តាមអំណានចម្លើយនៅដំណាក់កាលចៅក្រមស៊ើសួរថា កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ៧:០០នាទី ខ្លួនកំពុងនៅផ្ទះបម្រុងហ៊្នឹងងូតទឹកក៏លឺសំឡេងផាំង១ចំនួន ២ដង ខ្លួនស្មានតែសំឡេងគេបាញ់ផាវក៏ចេញមកក្រៅផ្ទះមើល ពេលចេញមកមើលលឺសមឡេងឈ្មោះ [redacted] ហាន ស្រែកថាចោរ១ ចោរបាញ់ជាងមាសហើយ ពេលលឺដូចច្នេះខ្លួនក៏នាំកូនរត់ចូលផ្ទះបាត់ទៅ។ ពេលកើតហេតុហើយបានប្រហែលជាកន្លះម៉ោង ខ្លួនក៏រត់ទៅមើលផ្ទះជនរងគ្រោះ ពេលទៅដល់ឃើញប្ដីរបស់ឈ្មោះ [redacted] ស៊ីណាត ដេកដួលនៅតៀនរោងបាយ បានមួយសន្ទុះក្រោយមកប្រពន្ធរបស់ជនរងគ្រោះក៏បញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យតែម្ដង។

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានទោសថា: ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី, សាក្សី, កំណត់ហេតុ, របាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងការស៊ើបសួររបស់ចៅក្រមស៊ើបសួរអាចកំណត់បានថា កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ វេលាម៉ោង ២០:២៥នាទី ស្ថិតនៅចំណុចខាងជើង ផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឪរ៉ាល់ ខេត្តកំពង់ស្ពឺ មានករណី លួចមានស្ថានទម្ងន់ទោសដោយសារមរណភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ថែទាំ ជួសជុល កែច្នៃ





តម្កើងនូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត មួយបានកើតឡើង ដែលបង្កឡើងដោយឈ្មោះ [redacted] សំអុល, ឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] យឿង ដែលបានធ្វើសកម្មភាពប្រើប្រាស់អាវុធម៉ាក AK ជាមធ្យោបាយបណ្ដាលឲ្យជនរងគ្រោះឈ្មោះ [redacted] ជឿន ជាម្ចាស់ផ្ទះបានបាត់បង់ជីវិត។ ក្រោយពេលធ្វើសកម្មភាពជនត្រូវចោទទាំងបីខាងលើបានរត់គេចខ្លួនបាត់។ ចំពោះឈ្មោះ [redacted] ម៉ុន្នា បានធ្វើសកម្មភាពលក់អាវុធម៉ាក AK ទៅឲ្យឈ្មោះ [redacted] សំអុល ហើយជននេះក៏បានយកទៅលក់ឲ្យឈ្មោះ [redacted] រី និងឈ្មោះ [redacted] វ៉ែន បន្តទៀត ដោយឡែកឈ្មោះ ឌី និងឈ្មោះ រ៉ាន់ ក៏មានជាប់ពាក់ព័ន្ធជាមួយនិងឈ្មោះ [redacted] សំអុល ក្នុងការចែកចាយអាវុធដោយគ្មានការអនុញ្ញាតផងដែរ។ មុននិងធ្វើសកម្មភាពឈ្មោះ [redacted] ស្រីសួគ៌ ត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] សំអុល បានទិញម្ហូបអាហាររៀបចំបាយទឹក ហើយថែមទាំងបានជូនឈ្មោះ [redacted] សំអុល ដោយជិះម៉ូតូទៅ ហើយក៏បានត្រឡប់មកវិញមុនផងដែរ ពិតប្រាកដមែន ហេតុដូច្នេះ តំណាងអយ្យការ សូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងសុំឲ្យចៅក្រមជំនុំជម្រះសម្រេចតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ធី, ឈ្មោះ [redacted] យឿង ហៅ អាយូន ឈ្មោះ [redacted] សំអុល ហៅ [redacted] សំអុល បានធ្វើសេចក្ដីសន្និដ្ឋានថា ក្រោយពីបានដេញដោលក្នុងពេលសវនាការឃើញថា កូនក្ដីរបស់ខ្លួនឈ្មោះ [redacted] វុទ្ធី ហៅ ធី និងឈ្មោះ [redacted] យឿង ហៅ អាយូន បានធ្វើសកម្មភាពរួមគ្នាជាឈ្មោះ [redacted] សំអុល ពិតមែន តែពួកកូនក្ដីខ្លួនទាំងពីរនាក់គ្រាន់តែទៅតាមឈ្មោះ [redacted] សំអុល ប៉ុណ្ណោះ ឃើញថាកូនក្ដីខ្លួនមិនមានចេតនាចូលរួមប្លន់ជាមួយឈ្មោះ [redacted] សំអុល នោះទេ ដូចនេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះប្ដូរបទចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ តាមមាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ មកជាបទ លួចមានស្ថានទម្ងន់ទោស តាមមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងសុំឲ្យបន្ធូរបន្ថយទោសដល់កូនក្ដីរបស់ខ្លួនតាមមាត្រា ៩៣, ៩៤ នៃក្រមព្រហ្មទណ្ឌ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ស្រីសួគ៌ បានធ្វើសេចក្ដីសន្និដ្ឋានថា ក្រោយពីបានដេញដោលក្នុងពេលសវនាការឃើញថា កូនក្ដីរបស់ខ្លួនត្រូវបានឃាត់ខ្លួនដោយសារតែការឆ្លើយដាក់របស់ឈ្មោះ [redacted] យឿង ហៅ អាយូន ប៉ុន្តែឈ្មោះ [redacted] យឿង ហៅ អាយូន បានអះអាងក្នុងពេលសវនាការឃើញថា [redacted] យឿង ហៅ អាយូន បានឆ្លើយថា ចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ឈ្មោះ [redacted] ស្រីសួគ៌ ជាអ្នកឧបឈ្មោះ [redacted] សំអុល មកកន្លែងកើតហេតុនោះ គឺពេលនោះមន្ត្រីយុត្តិធម៌បានសួរថា គឺឈ្មោះ [redacted] ស្រីសួគ៌ ជាអ្នកឧបមែនឬទេ ហើយឈ្មោះ [redacted] យឿង ហៅ អាយូន ឆ្លើយថា ប្រហែលហើយ និងនៅក្នុងដំណាក់កាលតំណាងអយ្យការ និងដំណាក់ចៅក្រមស៊ើបសួរ ឈ្មោះ [redacted] យឿង ហៅ អាយូន បានបដិសេធនូវចម្លើយនេះ ហើយបានបញ្ជាក់ថា កូនក្ដីខ្លួនឈ្មោះ [redacted] ស្រីសួគ៌ មិនបានដឹងពីសកម្មភាពប្លន់ដែលពួកគាត់ធ្វើជាមួយឈ្មោះ [redacted] សំអុល នោះទេ តាមចម្លើយរបស់ឈ្មោះ [redacted] យឿង ហៅ អាយូន និងសាក្សីឈ្មោះ

ពយ និងសាក្សីឈ្មោះ [redacted] សាម៉េត ដែលបានបញ្ជាក់ថាកូនក្តីខ្លួនក្នុងពេលកើតហេតុគឺនៅផ្ទះ មិនបានចេញទៅណានោះទេ ដូចនេះសំណូមសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះលើកលែងការចោទប្រកាន់ និងដោះលែងកូនក្តីរបស់ខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ធី និងឈ្មោះ [redacted] យឿង ហៅ អាយូន បានសំណូមពរសុំតុលាការ មេត្តាបន្ធូរបន្ថយទោសដល់ខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] ស្រីសួគ៌ និងឈ្មោះ [redacted] ម៉ុន្ថា បានសំណូមពរ សុំតុលាការមេត្តាលើកលែងការចោទប្រកាន់ដល់ខ្លួន។

-ក្រោយពីស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីស្តាប់ចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ស៊ុនរិទ្ធិ

-ក្រោយពីស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] យក់ហៀប

-ក្រោយពីស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវរួចហើយ

សាលាដំបូងខេត្តកំពង់ស្ពឺ

**<u>យល់ឃើញថា</u>**

-តុលាការបានទទួលបណ្តឹង តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥៤០ ចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ធី , ឈ្មោះ [redacted] យឿង ហៅ អាយូន , ឈ្មោះ [redacted] សំអុល ពីបទលួចមានស្ថាន ទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាម ខ្លួនកាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាត មកតុលាការដើម្បីជំនុំជម្រះពីបទៈ ឈ្មោះ [redacted] ម៉ុន្ថា ពីបទ បំពាក់ដាក់ តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ ប្រភេទដោយគ្មានការអនុញ្ញាត និងឈ្មោះ [redacted] ស្រីសួគ៌ មកតុលាការដើម្បីជំនុំជម្រះពីបទៈ សមគំនិតក្នុងអំពើ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទបំពាក់ដាក់តាមខ្លួន កាន់កាប់ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែសីហា ឆ្នាំ

២០១៦ តាមបញ្ញត្តិមាត្រា ២៩,៣៥៣,៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

-ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ធី បានឆ្លើយនាពេលសវនាការថា: កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ វេលាម៉ោងប្រែល ៥:៣០នាទីល្ងាច ឈ្មោះ [redacted] សំអុល បានហៅ ខ្លួនទៅផឹកនៅផ្ទះរបស់វាជាមួយឈ្មោះ [redacted] យឿង ហៅ អាយូន នៅពេលពីផឹកស៊ីឈ្មោះ [redacted] សំអុល បានបបួលខ្លួនទៅប្លន់ផ្ទះជាងមាស ពេលនោះឈ្មោះ [redacted] សំអុល បានឧបពួកខ្លួនទៅដល់ក្រោយផ្ទះជាងមាស ហើយមិនថាយកកាំភ្លើងមកពីណានោះទេ យកឲ្យឈ្មោះ [redacted] យឿង ហៅ អាយូន កាន់មួយដើម និងឈ្មោះ [redacted] សំអុល កាន់មួយដើម ពេលឈ្មោះ [redacted] សំអុល ក៏បានកាត់ខ្សែរលួសចំនួន ២ខ្សែរ ហើយឈ្មោះ [redacted] សំអុល ជាអ្នកចូលមុនគេ បន្ទាប់មកគឺឈ្មោះ [redacted] យឿន ហៅ អាយូន ចូល ខ្លួនជាអ្នកចូលក្រោយគេ មិនបានកាន់អ្វីនៅដៃនោះទេ ពេលចូលទៅដល់ក្រោយផ្ទះជាងមាស ឈ្មោះ [redacted] សំអុល បានជួបនិងម្ចាស់ផ្ទះនិងបានប្រតាយប្រតបគ្នា ហើយឈ្មោះ [redacted] សំអុល បានបាញ់ម្ចាស់ផ្ទះចំនួន ០១គ្រាប់ បន្ទាប់មកឈ្មោះ [redacted] យឿន ហៅ អាយូន បានបាញ់ទៅម្ចាស់ផ្ទះចំនួន ០១គ្រាប់ទៀត ខ្លួនឃើញដូចនេះរត់ចេញតែម្តង តែពេលរត់ចេញក៏ឮសំឡេងបាញ់ ០១គ្រាប់ទៀត តែមិនដឹងថាអ្នកណាជាអ្នកបាញ់នោះទេ។ ខ្លួនពិតជាបានចូលប្លន់ជាមួយឈ្មោះ [redacted] សំអុល និងឈ្មោះ [redacted] យឿន ហៅ អាយុ យូន ចំនួន ០៣លើក ពិតប្រាកដមែន។ ពីមុនមកខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] ម៉ុន្នា នោះទេ ទើបតែស្គាល់នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនប៉ុណ្ណោះ ចំណោះឈ្មោះ [redacted] ស្រីសូត មិនដឹងនិងចូលរួមការប្លន់របស់ពួកខ្លួនឡើយ។

-ជនជាប់ចោទឈ្មោះ [redacted] យឿង ហៅ យូន បានឆ្លើយនាពេលសវនាការថា: កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ វេលាម៉ោងប្រែល ៥:៣០នាទីល្ងាច ឈ្មោះ [redacted] សំអុល បានហៅ ខ្លួនទៅផឹកនៅផ្ទះរបស់វា ពេលផឹកស៊ីនោះមានឈ្មោះ [redacted] សំអុល ឈ្មោះ [redacted] វុទ្ធី ហៅ ធី និងរូបខ្លួន មិនមានឈ្មោះ [redacted] ស្រីសូត និងឈ្មោះ [redacted] ម៉ុន្នា នោះទេ នៅពេលពីផឹកស៊ីឈ្មោះ [redacted] សំអុល បានបបួលខ្លួនទៅប្លន់ផ្ទះជាងមាស នៅចម្ងាយពីផ្ទះរបស់ឈ្មោះ [redacted] សំអុល ប្រហែល ១គីឡូដី លុះដល់ម៉ោង ពេលនោះឈ្មោះ តឹក សំអុល បានឧបខ្លួននិងឈ្មោះ [redacted] វុទ្ធី ហៅ ធី ទៅដាក់នៅក្រោយផ្ទះរបស់ជាងមាស ហើយឈ្មោះ [redacted] សំអុល បានជិះម៉ូតូទៅយកកាំភ្លើងមកចំនួន ២ដើម តែមិនយកមកពីកន្លែងណានោះទេ ហើយបានឲ្យទៅឈ្មោះ យឹម វុទ្ធី ហៅ ធី កាន់មួយដើម ពេលនោះឈ្មោះ [redacted] សំអុល បានកាត់ខ្សែរលួសចំនួន ២ខ្សែរ ហើយឈ្មោះ [redacted] សំអុល ជាអ្នកចូលមុនគេ បន្ទប់មកខ្លួនចូលទៅតាមក្រោយ ហើយឈ្មោះ [redacted] វុទ្ធី ហៅ ធី ចូលមកដែរ ពេលចូលទៅដល់ឈ្មោះ [redacted] សំអុល បានជួបម្ចាស់ផ្ទះហើយបានប្រតាយប្រតប់ ឈ្មោះ [redacted] សំអុល ក៏បានបាញ់ទៅលើម្ចាស់ផ្ទះចំនួន ១គ្រាប់ ហើយខ្លួន[illegible] បាញ់ឡើងលើចំនួន ១គ្រាប់ ហើយឈ្មោះ [redacted] សំអុល ក៏បានបាញ់ចំនួន ០១គ្រាប់ទៀតទៅលើ

ជនគ្រោះ ខ្លួនក៏រត់ចេញមកតែម្តង។ ហើយខ្លួនមិនដែលស្គាល់ឈ្មោះ[redacted]ម៉ុន្នា នោះទេ គឺខ្លួនទើបតែស្គាល់នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនមកប៉ុណ្ណោះ នៅក្នុងករណីប្លន់នៅភូមិជំនាប់ ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺនោះ គឺមានឈ្មោះ[redacted]ប់អុល ឈ្មោះ[redacted] វុទ្ធី ហៅ ធី និងរូបខ្លួនតែប៉ុណ្ណោះ មិនមានឈ្មោះ[redacted]ស្រីស្ទត់ និងឈ្មោះ [redacted]ម៉ុន្នា នោះទេ។ ខ្លួននិងឈ្មោះ[redacted]សំអុល ឈ្មោះ[redacted]វុទ្ធី ហៅ ធី ធ្លាប់ប្លន់ចំនួន ៣លើកមកហើយ លើកទីមួយមានឈ្មោះ [redacted] ប៊ុនធឿន ឈ្មោះ [redacted] សំអុល ឈ្មោះ [redacted] វុទ្ធី ហៅ ធី និងរូមខ្លួន តែមិនបានធ្វើសកម្មភាពប្លន់នោះទេ ព្រោះខ្លួនជាអ្នកបង្អើលមិនឲ្យប្លន់ និងលើកទី ២ និងលើកទី៣ គឺមានតែបីនាក់ គឺឈ្មោះ [redacted] សំអុល ឈ្មោះ [redacted] វុទ្ធី ហៅ ធី និងរូបខ្លួន។ ចំពោះចម្លើយរបស់ដែលខ្លួនបានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ គឺពេលប៉ូលីសខ្លួនថា [redacted] ស្រីស្ទត់ បានឧបឈ្មោះ [redacted] សំអុល មកកន្លែងប្លន់មែនឬទេ ពេលនោះខ្លួនគ្រាន់តែឆ្លើយប្រហែលហើយ ហើយខ្លួនបានបដិសេធចម្លើយនេះតាំងពីដំណាក់កាលតំណាងអយ្យការ និងចៅក្រមស៊ើបសួររួចម្តងហើយ។

-ជនជាប់ចោទឈ្មោះ[redacted]ស្រីស្ទត់ បានឆ្លើយនាពេលសវនាការថា: កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ៥ទៅ៦ល្ងាច នៅក្នុងផ្ទះរបស់ខ្លួន មានឈ្មោះ[redacted] យឿង ហៅ អាយូន ឈ្មោះ [redacted] វុទ្ធី ហៅ ធី បានផឹកស៊ីជាមួយប្តីរបស់ខ្លួនឈ្មោះ[redacted]សំអុល ពេលនោះខ្លួនបានទៅទិញស្រាយកមកឲ្យពួកគាត់ផឹកនៅខាងក្រោយផ្ទះ ក្រោយពីទិញរួចហើយ ខ្លួនបានចូលទៅក្នុងផ្ទះមើលទូរទស្សន៍ និងចាក់ចម្រៀងស្តាប់នៅក្នុងផ្ទះ លុះដល់ម៉ោងប្រហែល ៦ល្ងាច ឈ្មោះ [redacted] យឿង ហៅ អាយូន និងឈ្មោ[redacted]ទ្ធី ហៅ ធី និងប្តីខ្លួនបានជិះម៉ូតូចេញទៅក្រៅបាត់ទៅ តែខ្លួនមិនដឹងថាទៅណានោះទេ រហូតមកដល់ម៉ោង ៨ភ្លឺ ទើបគាត់ត្រឡប់មកវិញ ហើយក៏ដោះអាវចូលដេកធម្មតា។ ចំពោះឈ្មោះ [redacted] វុទ្ធី ហៅ ធី និងឈ្មោះ[redacted] យឿង ហៅ អាយូន ខ្លួនស្គាល់ព្រោះពួកគាត់ជាជាងធ្វើផ្ទះឲ្យខ្លួន ហើយតែងតែដាំបាយឲ្យពួកគាត់ហូបពេលធ្វើផ្ទះ។ ចំពោះឈ្មោះ [redacted] ម៉ុន្នា ខ្លួនធ្លាប់ស្គាល់ ព្រោះពីមុនខ្លួនរស់នៅក្នុងបន្ទាយទាហាននៅត្រពាំងក្រឡឹង ហើយគាត់ជាទាហាននៅទីនោះ។ នៅថ្ងៃកើតហេតុខ្លួននៅផ្ទះមិនឧបប្តីខ្លួនឈ្មោះ[redacted]សំអុល ទៅម្តុំផ្ទះជាមាសនោះទេ។ ខ្លួនមិនដែលដឹងថាខ្លួនប្លន់គេជាច្រើនលក់នោះដែរ។

-ជនជាប់ចោទឈ្មោះ[redacted] ម៉ុន្នា បានឆ្លើយនាពេលសវនាការថា: កាលពីឆ្នាំ២០១៤ នៅខេត្តរតនៈគីរី ឈ្មោះ[redacted] សំអុល បានមកលេងកន្លែងស្នាក់នៅរបស់ខ្លួន ហើយបានឃើញកាំភ្លើងចាស់ច្រេះចាប់ ដែលខ្លួនទុកចោលនៅក្រោយផ្ទះ ហើយបានសុំខ្លួនថាយកកែច្នៃ ធ្វើកាំភ្លើងបាញ់សត្វ តែខ្លួនមិនឲ្យ ហើយឈ្មោះ [redacted]សំអុល ក៏បានត្រឡប់ទៅវិញ ក្រោយមកក៏បានមកម្តងទៀត ហើយបានសុំកាំភ្លើង ចាស់របស់ខ្លួនម្តងទៀត ពេលនោះខ្លួនគិតថាកាំភ្លើងនោះចាស់ហើយ ប្រើក៏មិនបានទៀត ដូច្នេះខ្លួនបានឲ្យកាំភ្លើងនោះទៅឈ្មោះ[redacted] [illegible]ទៅ តាំងពីថ្ងៃនោះមកខ្លួនមិនដែល បានជួបឈ្មោះ [redacted] សំអុល នោះទេ។ [illegible]

ដីកាកោះរបស់តុលាការខេត្តរតនៈគីរី ឲ្យខ្លួនទៅបំភ្លឺនៅតុលាការពាក់ពន្ធ័និងកាំភ្លើងរបស់ខ្លួន ដែលបានឲ្យទៅឈ្មោះ [redacted] សំអុល នោះ ក្រោយពីបំភ្លឺរួចមកតុលាការបានឲ្យខ្លួនត្រឡប់មកវិញ។ រហូតដល់មានករណីប្លន់ស្រុក ឪពល់ក៏ខ្លួនមិនបានដឹងនោះដែរ ស្រាប់តែមានដីកាបញ្ជាឲ្យចូលខ្លួន ហើយបានចាប់ឃាត់ខ្លួនតែម្តង ចំពោះករណីនេះខ្លួនមិនបានដឹងនោះទេ ហើយក៏មិនដែលបានលក់កាំភ្លើងឲ្យឈ្មោះ [redacted] សំអុល នោះដែរ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីណាត បានឆ្លើយនាពេលសវនាការថាៈ កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ៦ជាងល្ងាច ខ្លួនកំពុងថ្ងះជាមួយកូននៅខាងមុខផ្ទះ ហើយប្តីរបស់ខ្លួននៅដងទឹកខាងក្រោយផ្ទះ ពេលនោះបានឮសំឡេងប្តីរបស់ខ្លួនស្រែកថាចោរប្លន់ហើយ ពេលនោះខ្លួនក៏បានរត់ទៅមើល តែពេលទៅដល់ប្តីរបស់ខ្លួនដេកដួលនៅនិងដីទៅហើយ ហើយខ្លួនក៏បាននាំគាត់ទៅមន្ទីរពេទ្យ ហើយប្តីរបស់ខ្លួនក៏បានស្លាប់បាត់ដែរ ។ ខ្លួនទាមទារសំណងជំងឺចិត្តចំនួន ៥០.០០០(ប្រាំម៉ឺនដុល្លារ)។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ធី, ឈ្មោះ [redacted] យឿង ហៅ អាយូន ឈ្មោះ [redacted] សំអុល ហៅ [redacted] សំអុល បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានដេញដោលក្នុងពេលសវនាការ ឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] វុទ្ធី ហៅ ធី និងឈ្មោះ [redacted] យឿង ហៅ អាយូន បានធ្វើ សកម្មភាពរួមគ្នាជាឈ្មោះ [redacted] សំអុល ពិតមែន តែពួកកូនក្តីខ្លួនទាំងពីរនាក់គ្រាន់តែទៅតាមឈ្មោះ [redacted] សំអុល ប៉ុណ្ណោះ ឃើញថាកូនក្តីខ្លួនមិនមានចេតនាចូលរួមប្លន់ជាមួយឈ្មោះ [redacted] សំអុល នោះទេ ដូចនេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះប្តូរបទចោទប្រកាន់ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ តាមមាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ មកជាបទ លួចមានស្ថានទម្ងន់ទោសតាមមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងសុំឲ្យបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួនតាមមាត្រា ៩៣, ៩៤ នៃក្រមព្រហ្មទណ្ឌ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ស្រីសួគ៌ បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានដេញដោលក្នុងពេលសវនាការឃើញថា កូនក្តីរបស់ខ្លួនត្រូវបានឃាត់ខ្លួនដោយសារតែការឆ្លើយដាក់របស់ឈ្មោះ [redacted] យឿង ហៅ អាយូន ប៉ុន្តែឈ្មោះ [redacted] យឿង ហៅ អាយូន បានអះអាងក្នុងពេលសវនាការឃើញថា [redacted] យឿង ហៅ អាយូន បានឆ្លើយថា ចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ឈ្មោះ [redacted] ស្រីសួគ៌ ជាអ្នកឧបឈ្មោះ [redacted] សំអុល មកកន្លែងកើតហេតុនោះគឺពេលនោះមន្ត្រីយុត្តិធម៌បានសួរថា គឺឈ្មោះ [redacted] ស្រីសួគ៌ ជាអ្នកឧបមែនឬទេ ហើយឈ្មោះ [redacted] យឿន ហៅ អាយូន ឆ្លើយថា ប្រហែលហើយ និងនៅក្នុងដំណាក់កាលតំណាងអយ្យការ និងដំណាក់ចៅក្រមស៊ើបសួរ ឈ្មោះ [redacted] យឿង ហៅ អាយូន បានបដិសេធនូវចម្លើយនេះ ហើយបានបញ្ជាក់ថា កូនក្តីខ្លួនឈ្មោះ [redacted] ស្រីសួគ៌ មិនបានដឹងពីសកម្មភាពប្លន់ដែលពួកគាត់រៀបចំជាមួយឈ្មោះ [redacted] សំអុល នោះទេ តាមចម្លើយរបស់ឈ្មោះ [redacted] យឿង ហៅ អាយូន និងសាក្សីឈ្មោះ [redacted] ពយ និងសាក្សីឈ្មោះ [redacted] សាម៉េត ដែលបានបញ្ជាក់ថាកូនក្តីខ្លួនក្នុងពេលកើតហេតុនៅផ្ទះ

មិនបានចេញទៅណានោះទេ ដូចនេះសំណូមសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះលើកលែងការចោទប្រកាន់ និងដោះលែងកូនក្ដីរបស់ខ្លួន។

-ដើមបណ្ដឹងរដ្ឋប្បវេណី បានទាមទារសំណងជំងឺចិត្តចំនួន ៥០.០០០(ប្រាំម៉ឺនដុល្លារ) គប្បីតុលាកានិងលើកយកមកធ្វើការពិចារណាសម្រេចតាមច្បាប់។

-ជនជាប់ចោទជានីតិជន ដែលមានសមត្ថភាពអាចយល់ដឹងពីអំពើរបស់ខ្លួន ហើយខ្លួននៅតែប្រព្រឹត្តដោយចេតនាទុច្ចរិតតាមឆន្ទៈរបស់ខ្លួន ដែលច្បាប់បញ្ញត្តិថាជាបទល្មើស និងត្រូវផ្ដន្ទាទោស ។

-អំពើរបស់ជនជាប់ចោទដែលបានប្រព្រឹត្ត ធ្វើឲ្យប៉ះពាល់អាយុជីវិតរបស់ជនទៃ របៀបរៀបរយសារធារណៈ និងសន្តិសុខសង្គម។

-វត្ថុតាងដែលមានក្នុងកំណត់ទទួលវត្ថុតាង ដែលកំណត់ហេតុទទួលវត្ថុតាងរួមមាន កាំភ្លើងចំនួនអាកា(AK) ៤ចំនួនដើម ស្នាយបត់ចំនួន ០១ដើម មានលេខតួ ១៦២៣៨៣២ និងស្នាយកាត់៣ដើមមានលេខតួ ៥៣១៩៥៥៤, លេខតួ ៥៣១៨៨៩១, លេខតួ ៥៣២១៥៥២ , បង់ចំនួន ០៤បង់ , គ្រាប់ចំនួន ៨៦គ្រាប់ ស្នាប់ដៃចំនួន ០២ , ស្នាយដោះចេញចំនួន ០២, គល់អុស ចំនួន ០២កំណាត់ , ធុងប៉េត្រូចំនួន ០១ពណ៌ស សង្ក័សីមួយផ្ទាំង, ពិល ០១ពណ៌ក្រហម , ដង្កាប់ ០១ , ក្ដារវីកំបោ ២ជំរពណ៌ខៀវ , ស្លាបព្រាដែករៀបឥដ្ឋ ០១ , កន្ត្រៃកាត់ដែក ០១ , ដងកន្ត្រៃកាត់ ដែក ០២ , ម៉ែត្ររមូ ០១ខ្ចូចពណ៌ខៀវ , អាវប៉ាក់ដៃវែង ០២ , ខោប៉ាក់ជើងវែង ០១ , ខ្សែកាំភ្លើង ០២ , ស្បែកជើងផ្ទាត់ ០៣គូ , ស្បែកជើងបាត់តា ០១គូ ក្រណាត់ខោជើងវែង ០២ , អាវយឺតដៃខ្លីពណ៌ក្រហម ០១ , មួកយឺតពណ៌ខ្មៅក្រៅក្រហមក្នុង ០១ , ខោលីអូពណ៌ខៀវ ០១ , អាវដៃវែងឆ្នូតពណ៌សលាយទឹកប៊ិច ០១ , ក្រណាត់កៅស៊ូ ពណ៌ស ០១ផ្ទាំង ថង់កាតេតពណ៌ស ០៣ ពណ៌លឿង ០១ , ថង់ប្លាស្ទិចពណ៌ស ០១ ពណ៌លឿង ០១ , សំបកគ្រាប់ធុន ៧៦២មម x ៣៩មម ចំនួន ០៣ សំបក មានលេខសំគាល់តួថ ២៧០ ពណ៌ទង់ដែងដូចគ្នា និងដង្កាប់ដែក ០១ ដងស្រោមជ័រពណ៌លឿងលាយខ្មៅ(សង្កាប់ថ្មី) តុលាការគប្បីសម្រេចរឹបអូសទុកជាសម្បត្តិ។

-តាមចម្លើយជនជាប់ចោទឈ្មោះ[redacted]យឿង ហៅ អាយូន ឈ្មោះ [redacted] វុទ្ធី ហៅ ធី ដែលបានឆ្លើយថា ក្នុងគំរោងការប្លន់ទាំងបីលើកនេះ ឈ្មោះ [redacted] ស្រីសួគ៌ មិនបានដឹងនោះទេ ព្រោះពេលរៀបចំគំរោងការម្ដងៗ គឺមានតែឈ្មោះ [redacted] សំអុល ឈ្មោះ[redacted]យឿង ហៅ អាយូន និងឈ្មោះ [redacted] វុទ្ធី ហៅ ធី តែប៉ុណ្ណោះ ដែលតែងតែពិភាក្សាគ្នារៀបចំប្លន់ ចំពោះឈ្មោះ [redacted] ស្រីសួគ៌ មិនមានជាប់ពាក់ព័ន្ធនឹងករណី ប្លន់ នៅភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឪរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៧ នោះទេ ដូច្នេះគប្បីតុលាការសម្រេចឲ្យជនជាប់ចោទឈ្មោះ[redacted] ស្រីសួគ៌ ភេទស្រី អាយុ ២២ឆ្នាំ រួចផុតបទចោទប្រកាន់ពីបទ សមគំនិត ក្នុងអំពើ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឪរ៉ាល់ ខេត្តកំពង់ស្ពឺ

កាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, ៣៥៣, ៣៦០ នៃ ក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] យៀង ហៅ អាយូន ឈ្មោះ [redacted] វុទ្ធី ហៅ ធី ដែលបានឆ្លើយបញ្ជាក់ថា ពីមុនមកខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] ម៉ុន្ថា នោះទេ ហើយនៅក្នុងពេលកើតហេតុក៏មិនមានឈ្មោះ [redacted] ម៉ុន្ថា ចូលរួមនោះដែរ និងកាំភ្លើងដែលឈ្មោះ [redacted] សំអុល យកមកនោះ គឺខ្លួនមិនបានដឹងថាឈ្មោះ [redacted] សំអុល យកមកពីណានោះទេ ដូចនេះតប្បីតុលាការសម្រេចឲ្យរួចផុតបទចោទប្រកាន់លើឈ្មោះ [redacted] ម៉ុន្ថា ភេទប្រុស អាយុ ៥៨ឆ្នាំ ពីបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រង អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

-ជនជាប់ចោទឈ្មោះ [redacted] ម៉ុន្ថា ដែលត្រូវបានតំណាងអយ្យការអមសាលាដំបូងខេត្តរតនៈគីរី ចោទប្រកាន់ពីបទ ធ្វើចរាចរណ៍អាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត តាមមាត្រា ២៨ និងមាត្រា ៥៨ នៃក្រមព្រហ្មទណ្ឌ តែត្រូវបានលើកលែងការចោទប្រកាន់តាមដីកាដំណោះស្រាយរបស់សាលាដំបូងខេត្តរតនៈគីរីលេខ ១៨០៦ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៤ និងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ុន្ថា និងសាក្សីឈ្មោះ [redacted] សុផៃ ជាឧត្តមសេនីទោនៃបញ្ជាការដ្ឋានរថក្រោះ បានបញ្ជាក់ថា អង្គភាពរថក្រោះ ក្រោយពីបានបាត់កាំភ្លើងរួចមក អង្គភាពបានបង្កើតគណៈកម្មការដើម្បីត្រួតពិនិត្យលើករណីបាត់កាំភ្លើងនេះ ឃើញថាកាំភ្លើងដែលបាត់នោះ គឺបាត់នៅក្នុងឆ្នាំ២០១៦ មិនមែនបាត់នៅឆ្នាំ២០១៤ នោះទេ ហើយអង្គភាពបានសន្និដ្ឋានថា កាំភ្លើងដែលបានបាត់នោះគឺឈ្មោះ [redacted] សំអុល ជាអ្នកលួចយកទៅ នៅពេលដែលឈ្មោះ [redacted] សំអុល ត្រូវដោះលែងពីពន្ធនាគារខេត្តរតនៈគីរី ហើយបានមកបង្ហាញខ្លួននៅអង្គភាពរថក្រោះអាសេអូ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា រក្សាបទចោទប្រកាន់របស់ខ្លួនទុកជាបានការដដែល និងសុំចៅក្រមជំនុំជំរះសម្រេចផ្តន្ទាទោសជនជាប់ចោទផ្លូវច្បាប់។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើ ដើម្បីផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ហៅ ធី, ឈ្មោះ [redacted] យៀង ហៅ អាយូន និងឈ្មោះ [redacted] សំអុល ហៅ [redacted] សំអុល ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់ តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី



CamScanner

១៥ ខែមេសា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ។

## សាលាដំបូងខេត្តកំពង់ស្ពឺ
## វិនិច្ឆ័យសេចក្តី

១.ឲ្យរួចផុតពីបទចោទប្រកាន់លើឈ្មោះ [redacted] ស្រីសួគ៌ ភេទស្រី អាយុ ២២ឆ្នាំ (ដែលមានសវតាជាតិដូចខាងលើ) ពីបទ: សមគំនិត ក្នុងអំពើ លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជូល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩, ៣៥៣, ៣៦០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

២.ឲ្យរួចផុតពីបទចោទប្រកាន់លើឈ្មោះ [redacted] ម៉ុន្នា ភេទប្រុស អាយុ ៤៨ឆ្នាំ (ដែលមានសវតាជាតិដូចខាងលើ) ពីបទ: បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជូល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅ ភូមិផ្សារកន្ទួត ឃុំ សង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

៣.ផ្តន្ទាទោសលើជនជាប់ចោទ:

ក.ឈ្មោះ [redacted]ទុន្ធី ហៅ ធី ភេទប្រុស អាយុ ៣៧ឆ្នាំ (ដែលមានសវតាជាតិដូចខាងលើ)។

ខ.ឈ្មោះ [redacted] ឃឿន ហៅ អាឃួន ភេទប្រុស អាយុ ៣៥ឆ្នាំ (ដែលមានសវតាជាតិដូចខាងលើ)។

ម្នាក់ៗដាក់ពន្ធនាគាររយៈពេល ២០ឆ្នាំ ពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជូល កែច្នៃ តម្លើងនូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិផ្សារកន្ទួត ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ១៥ ខែ មេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

៤.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សំអុល ហៅ [redacted] សំអុល ភេទប្រុស អាយុ ៣២ឆ្នាំ (ដែលមានសវតាជាតិដូចខាងលើ) ដាក់ពន្ធនាគាររយៈពេល ២៥ឆ្នាំ ពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារមរណៈភាពជនរងគ្រោះ និងបទ បំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឲ្យខ្ចី ផ្ទេរ ចែកចាយ ជូល កែច្នៃ តម្លើងនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់



CamScanner